# ជួបភក្ត្រ ជំពាក់ចិត្ត

មើលផ្ទៃមេឃមានពណ៌ខៀវស្រងាត់ ព្រះពាយផាត់រសាត់លឿនលយ
ផ្ការីកក្រអូបសុសសាយ ឱរាឆ្ងាយក្តីកង្វល់។

ហ៊ឹ ហ៊ឹ ហ៊ឹ ហ៊ឹ ហ៊ឹ ហ៊ឹ ... ហ៊ឹ ហ៊ឹ... ក្រអូបពិតចិត្តសែនអំពល់
ផ្កាស្រស់រេរាំតាមខ្យល់ ចិត្តចង់ស្គាល់ក្លិនបុប្ផា។

នែ៎ សុំប្រយ័ត្នសម្ដី ក្រែងមានភ័យព្រោះវាចា
ចិត្តអ្វីធំម្ល៉េះប៉ងបេះបុប្ផា មកពីណាប្រាថ្នារកអ្វី។

ខ្ញុំសូមទោស បើសិនមានខុសឆ្គង ប្រុសគ្មានប៉ងលួចចងមេត្រី
ត្រង់ស្មោះគ្មានបំណងអ្វី សូមប្រណីអត់ទោសផង។

បេញទៅ កុំនៅតវ៉ា មិនត្រូវការមកឆ្លើយឆ្លង
មេត្តាសន្តោស បើមានខុសឆ្គង កុំផ្តោះផ្តង ប្រយ័ត្នខ្ញុំវាយ។

ហ្អូ ... បើវាយខ្ញុំ ខ្ញុំក៏មិនខឹងទេ ទោះជាជេររឹតតែរីករាយ
ព្រោះតាមបណ្តាំអ្នកម្តាយ ស្រីណាហ៊ានវាយ ស្រីហ្នឹងគូខ្ញុំ។

**បទចម្រៀងកាលពីសម័យឆ្នាំ១៩៦០-១៩៧០**
**ពុំដឹងឈ្មោះអ្នកនិពន្ធ**

# ២

ព្រះសុរិយាបើកឱភាសច្បាស់ស្រឡះលើឮដ៏មេឃា។ ជំនោរខែកក្កិកធ្លាក់មករអឹក គួរឱ្យព្រឺព្រួច ... បក្សាបក្សីស្រែកហួចច្រៀងអន្ទងរកគូលើចុងព្រឹក្សា... បុស្បាផ្កាព្រៃក៏ប្រជែងគ្នារីកចោលគន្ធពិដោរក្រអូបសាយ។

នៅក្បែរមាត់អូរដែលមានទឹកហូររឹមៗ សំលេងមនុស្សច្រៀងលាន់រហ៊ឹម... ស្រមោលមួយរាងតូចសង្ហិល កំពុងរំកិលធ្វើដំណើរយឺតៗនិងឈប់ឈរជាច្រើនអន្លើ ... លុះមកដល់ដើមមហាហង្សដែលមានផ្កាពណ៌លឿងទុំនិងពណ៌ក្រហម ខ្លះរីកខ្លះក្រពុំលាយឡំចម្រុះគ្នា ម្ចាស់ស្រមោលក៏ឈប់ម្ដងទៀត លាន់មាត់ខ្សឹបៗ "ឱ ផ្កានេះក៏ស្អាតដែរ! បេះថែមទៀតសិន ... លោកយាយច្បាស់ជាពេញចិត្ត ... លោកបងប្រសិទ្ធលាចាកផ្នួសថ្ងៃនេះផង ត្រូវតែក្រងភួងមាលាមួយយ៉ាងស្អាតបំផុត ទុកបំពាក់ឱ្យគាត់ ពេលគាត់ចេញពីវត្ត ... ហ៊ឺ ... ហ៊ឺ ... ហ៊ឺ..." ម្ចាស់សំនៀងឱបបាច់បុប្ផាព្រៃមួយសំណុំធំទៅហើយ តែនៅខំងើយមុខមើលទៅចុងមែកមហាហង្ស និងប្រឹងចំទើតជើងឈោងដៃស្ដាំទៅរកទងផ្កាមួយ តែបុប្ផាឋិតនៅខ្ពស់ហួសឆ្ងាយពីហត្ថាបន្តិចម្ចាស់ដៃក៏ខំប្រឹងលោតផ្ទោតៗ ក្នុងបំណងចាប់ទាញមែករុក្ខាឱ្យទោរចុះមកនឹងអាលខ្លួនបេះយកផ្កាល្អស្រស់នៅចុងមែកតាមប្រាថ្នា ... ស្រាប់តែរំពេចនោះ មានហត្ថមួយលូកមកកាច់បុប្ផាទាំងទង ទាញយកទៅបាត់!

ជនទីមួយបែរក្រោយឥតបង្អង់ បានឃើញជនទីពីរកំពុងកាន់ផ្កាមហាហង្សដ៏ស្រស់ស្អាតក្នុងដៃ ក៏ចងចិញ្ចើម ពោលដោយមិនសប្បាយចិត្ត "នែ៎ អ្នក! ផ្កាហ្នឹងជារបស់ខ្ញុំទេ ... ឆាប់ប្រគល់មកឱ្យខ្ញុំវិញ!"





ជនទីពីរដកភ្នែកពីសំណុំបុប្ផាក្នុងដៃ ងើបមុខសម្លឹងមកនារីម្ចាស់សម្ដី ហើយបញ្ចេញផ្កាញញឹមយ៉ាងស្រស់ តែធ្វើឫកដូចជាភ្ញាក់ "អីចឹងឬ?..." គេបង្វិលទងបុប្ផាក្នុងដៃ "តើមានភស្តុតាងអីបញ្ជាក់ថានេះជាផ្ការបស់នាង?"

នារីបើកភ្នែកធំៗសម្លក់បុរសចំពោះមុន "អ្នកមិនឃើញទេឬ ថាខ្ញុំកំពុងចង់បេះផ្កាមួយទងហ្នឹង ម្ដេចមកដណ្ដើមបេះយកទៅមុនបាត់?"

"ហ្អេស ... ផ្កាដុះដោយព្រៃ មិនមែនជាកម្មសិទ្ធិផ្ដាច់មុខអីរបស់នាងឯណា? អ្នកណាបេះបានមុន ជារបស់អ្នកនោះហើយ!..." បុរសស្រដីបែបព្រងើយធ្វើឱ្យនារីកើតក្ដីគ្នាន់ក្នាញ់ លើកដៃចង្អុលមុខគូបដិបក្ខ "យី អ្នកនេះចំជាឥតមារយាទ! ... បេះឡៀតមកដណ្ដើមរបស់គេឥតខ្មាស ... ផ្កាមានច្រើនណាស់ពេញតែដើម ម្ដេចមកច្រូលជ្រើមដណ្ដើមយករបស់ដែលគេប៉ងហើយ?!"

ឃើញនារីទំនងជាខឹងខ្លាំង បុរសក៏ពោលសម្របសម្រួល "ណ្ហើយ ខ្ញុំឱ្យផ្កាមួយទងនេះទៅនាងក៏បាន ... តែនាងត្រូវពោលពាក្យសុំឱ្យទន់ភ្លន់បន្តិចមកបំណាច់នឹងខ្ញុំខំឈោងដៃបេះយកមកបាន ... រំពឹងលើកម្ពស់របស់នាង បើទោះជាខំប្រឹងលោតដល់ល្ងាចឬក៏ស្អែក ក៏បេះផ្កានេះពុំបានដែរ!"

នារីពេបមាត់ ហើយឆ្លើយ "ហ៊ឹះ មនុស្សគម្រក់! ... មកដណ្ដើមយករបស់គេទៅហើយ បែរជាធ្វើឫកឈ្មើយនិងមានមុខមកឱ្យគេអង្វរករសុំវិញ ... យើងមិនខ្ជីសុំទេ! ... បើចង់បានណាស់ អញ្ជើញយកទៅចុះនរកចុះ!"

"ពុទ្ធោ!..." បុរសលាន់មាត់ "មុខមាត់ស្អាតបាត ម្ដេចសម្ដីអាក្រក់អាក្រីម្ល៉េះ? គ្រាន់តែផ្កាមួយទង ដាក់បណ្ដាសាឱ្យគេចុះនរក?"

នារីមិនខ្ជីស្ដាប់ បែរមុខដើរចេញ។

បុរសប្រញាប់រត់តាម "នាងអូនអើយ ឈប់សិន! ... បងសុំទោស ... នាងអូនយកផ្កានេះទៅចុះ បងសុខចិត្តប្រគល់ឱ្យនាងហើយ!..."

នារីមិនបង្អង់ជើង មិនបែរក្រោយ តែឆ្លៀតឆ្លើយថា "មិនយកទេ!"
បុរសខំបង្កើនល្បឿន រត់មកស្កាត់ពីមុខតរុណី "នាងអូនកុំខឹងអី ... បងគ្រាន់តែលេងបន្តិចទេតើ ... ណោះ យកទៅណានាងអូន!..."
មាណពហុចផ្កាមកឱ្យមាណវី តែនារីលើកដៃគ្រវាសចេញ ធ្វើមុខក្រញូវ "មិនត្រូវការទេ! ... លោកឯងមិន ចេះស្ដាប់ខ្មែរទេឬ?"
បុរសស្រាប់តែលើកផ្កាទៅថើប "ហ៊ឺ ក្រអូបណាស់ ... មិនយកច្បាស់ជាស្ដាយក្រោយហើយ!..."
នារីធ្វើមុខដូចចង់ក្អួត "ខ្ពើមណាស់! ... ផ្កាមហាហង្សឯណាមានក្លិនក្រអូប? ចំជាឡប់សតិមែន! ... ឆាប់ចេញពីមុខខ្ញុំភ្លាមទៅ កុំមកនៅរាំងផ្លូវគេ!"
បុរសឈប់ថើបផ្កា តែក៏មិនព្រមបើកផ្លូវ "មិនចេញទេ ទាល់តែនាងអូនឈប់ខឹងនឹងបងសិន!..." រួចគេទម្លាក់សំលេងពោលយ៉ាងទន់ភ្លន់ "កុំធ្វើមុខក្រញូវអីចឹង នាំតែខូចសម្រស់ភក្ត្ររបស់នាងអូនអស់ ... ស្ត្រីមានរូបល្អ គួរតែមានសម្ដីនិងចិត្តល្អដែរណ៎ា ទើបពេញចំជាស្ត្រីល្អពិត!..." បុរសញញឹមស្រស់ "បងឈ្មោះចំរុង ... តើនាងអូនឈ្មោះអីដែរ?"
នារីមិនឆ្លើយ តែសម្លឹងបុរសឈ្មោះចំរុងចុះឡើងដោយភក្ត្រក្រញូវដដែល។ បុរសក៏បណ្ដោយឱ្យនារីសម្លឹងតាមចិត្ត ដោយឥតបន្ថយស្នាមញញឹមឡើយ គេមានរូបរាងសង្ហា ក្នុងវ័យប្រមាណជាម្ភៃឆ្នាំ សម្បុរស្រអែម សក់រួញតិចៗ កែវភ្នែកភ្លឺថ្លា ... គេពាក់អាវវាល-កដៃខ្លីពណ៌ស្វាបកំភេម ស្លៀកខោខ្លីនពណ៌បៃតងក្រមៅ ទម្លាក់ជើងមកជិតដល់ក្បាលជង្គង់ មានក្រវាត់ចង្កេះជាក្រមាពណ៌ត្រួយល្ងៀប និងមានសៀតកូនកាំបិតស្ថិតនៅក្នុងស្រោមស្បែកលើកណ្ដៀតក្អមខាងឆ្វេងផង។ សម្លៀកបំពាក់ចាស់ជំនុំ ការតុបតែងខ្លួនក៏មានសភាពសាមញ្ញ ពុំខុសអ្វីពីបុរសអ្នកជាទូទៅនៅក្នុងភូមិ ... ប៉ុន្តែសំនៀងនៃ





សម្ដីសំដៅរបស់គេពុំដូចអ្នកស្រុកធម្មតាឡើយ។
បន្ទាប់សម្លឹងសម្ងក់បុរសរូបសង្ហាអស់មួយស្របក់ យុវតីក៏ស្រដីដោយចង់ចិញ្ចើមក្រញឹង "ចៀសចេញ! ... កុំឱ្យខ្ញុំដេញច្រើនដង ... បើមកប៉ងចេញម៉េតប្រាយលែបខាយវាចា ធ្វើជាព្រាននារីឥតពូជឥតអម្បូរ ប្រយ័ត្នខ្ញុំមិនទុកមុខឱ្យវិញ! ឆាប់ចេញពីផ្លូវខ្ញុំភ្លាម!"
បុរសនៅឈរនឹងថ្កល់ត្រង់កន្លែងដើម "ផ្លូវជាផ្លូវសម្រាប់មនុស្សម្នាទូទៅ ពុំមែនជាផ្លូវរបស់នាងអូនតែម្នាក់ឯងឯណា ... បងពេញចិត្តឈរនៅទីនេះ តើនាងអូនគិតដូចម្ដេចទៅ?"
"បើមិនព្រមចេញតាមសម្រួលទេ តិចខ្ញុំវាយឱ្យមុខបែកឥឡូវ!..." នារីស្រែកគំរាម ថែមទាំងលើកដៃស្ដាំឡើងផង។
បុរសឈ្មោះចំរុងជញ្ជក់មាត់ "រូបក៏បាន សម្ដីក៏ក្លាហាន ទាស់តែចិត្តអាក្រក់... បើនាងអូនចង់វាយបង ក៏វាយមកចុះតាមចិន្ដា ... ព្រោះអ្នកម្ដាយបងលោកបានផ្ដាំថា បើនារីណាហ៊ានលើកដៃវាយបង ទំនាយថានាងនោះជាគូព្រេងរបស់បងជាប្រាកដណាស់!"
នារីមានមុខក្រហម នាងទម្លាក់ដៃចុះ ប្រើភ្នែកសម្ងក់ខ្មៅរវិញម្ដង "មុខក្រាស់! មនុស្សបែបអ្នកឯងច្បាស់ជាត្រូវរន្ទះបាញ់ស្លាប់ឆាប់ៗនេះមិនខាន!"
"ឱ ចេះពោលពាក្យឱ្យពរបងបានពិរោះណាស់!..." បុរសនៅញញឹមស្រស់ "បើបងត្រូវរន្ទះបាញ់ស្លាប់ ច្បាស់ជាចាប់ជាតិជាខែតាមតោងនាងអូនជាប់មិនឱ្យរបេះឡើយ!"
មុខនារីកាន់តែក្រហម "មនុស្សមាត់ចង្រៃ! ... ទោះជាកើតជាខែក៏មិនបានមកនៅក្បែរយើងដែរ កុំសង្ឃឹម!" ពោលចប់ នាងក្រមុំបោលសំរុកទៅមុខ ដោយយកស្មាបុកដើមទ្រូងបុរសផាំង! ធ្វើឱ្យនរៈខ្វាតចេញពីកន្លែងដើម លែងធ្វើ

ជារបាំងពាំងផ្លូវនាងទៀត ... យុវតីធ្វើដំណើរចេញទៅយ៉ាងលឿន។
ក្រមុំតូចកំពុងតែដើរប៉ាត់រញ៉ាត់រលេះរលាំងមកដល់ជិតមាត់ផ្លូវចូលទៅក្នុងភូមិវាលអន្ទង់វិល ស្រាប់តែមានស្រមោលមួយហក់មកស្កាក់ផ្លូវនាងទៀត។ ដោយមានទោសៈជាប់ក្នុងចិត្តស្រាប់ផង តរុណីស្រែកគំហកដោយពុំចាំបាច់មើលមុខអ្នកស្កាក់ផ្លូវ "ចៀសចេញ!..."
សំណើចក្អាកក្អាយក៏លាន់រំពងឡើង អមដោយវាចាបែបលែបខាយចែចង់ "សួស្តីស្រីស្រស់! ... តើប្រញាប់ទៅណា? ... នៅចរចាកំសាន្តនឹងបងសិន!"
នាងក្រមុំដកដង្ហើមធំ "តើថ្ងៃនេះជាថ្ងៃចង្រៃអ្វីទៅហ្ន៎ ទើបមកជួបមនុស្សចិត្តចោរម្តងជាពីរដង?"
បុរសអស់សំណើចក្អាកក្អាយជាថ្មី "យីនាងអូនស្គាល់បងច្បាស់ម៉្លេះ ... បងគឺជាចោរមែនហើយ!" គេលើកដៃទះទ្រូងដែលចំហទទេ គ្មានអ្វីបិទបាំងឡើយ "បងមាននាមថា មេចោរស្នេងតាន់! ... អ្នកស្រុកអ្នកភូមិឱ្យតែឮឈ្មោះបងតែងខ្លបខ្លាច តែក្អកក៏មិនហ៊ានផង! ... បងពេញចិត្តនឹងរូបស្រស់នួនល្អងពេកណាស់ ចង់បានអូនធ្វើប្រពន្ធតែម្តង! ... ព្រមដោយបងតាមសម្រួលទៅពៅព្រលឹង..."
មេចោរស្នេងតាន់លូកដៃមករកបិចចង្កាស្រស់ស្រី តែតរុណីគ្រវាសចេញភ្លាម "ចំជាឥតកេរ្តិ៍ឥតខ្មាស ហ៊ានមកប្រកាសខ្លួនជាចោរដោយចំហ! ... យកល្អត្រូវថយចេញពីមុខយើងឱ្យឆាប់! ... មិនអីចឹងទេ យើងទៅប្រាប់អ្នកស្រុកឱ្យមកចាប់អូស-ក យកទៅកាប់ចោលឥឡូវនេះឯង!" ពោលហើយ នាងក្រមុំបោលសំរុកបុកប្រាណបុរសមេចោរ។
ប៉ុន្តែលើកនេះ មិនដូចលើកមុនឯណា ... បុរសមេចោរមានមាឌមាំ សម្បុរខ្មៅស្រិលដូចលាបម្រ័ក្សណ៍ ... ស្បៀកតែក្បិនពណ៌ខ្មៅខើចខ្ចីដល់គល់ភ្លៅ



ក្រៅពីស្លាយដាវក្នុងស្រោមមួយនៅលើខ្នង អង្គកាយគេផ្នែកខាងលើគ្មានអ្វីបិទបាំងឡើយ ... ដើមទ្រូងដែលមានតែខ្សែដាវពាក់ឆៀង បង្ហាញនូវសាច់ដុំធំមាំទាំងផ្ទាំង ... ពេលត្រូវនារីបុកផាំង គេនៅឈរផ្ទាំងគ្មានរង្គើប្រាណអ្វីបន្តិច ... គេស្រវាចាប់ឱបនារីតូចតន់ក្នុងរង្វង់ដៃតែម្តង។
តរុណីរើបម្រះ ស្រែកឆោឡោ "លែង! ... លែងយើង អាចោរគម្រក់!"
បុរសមេចោរសើចរលាក់ "លែងទៅណា ប្រពន្ធសម្លាញ់? ឱ្យបងសុំថើបមួយ!"
បុរសឱនមុខចុះ ប្រុងដាក់ច្រមុះលើថ្ពាល់ដែលក្រហមដូចម្ទេសទុំ ... នារីក៏លើកបាច់ផ្ការុញផ្ទុកទៅលើមុខមេចោរ ខំរើផង ជាក់ផង និងស្រែកដេរចេចចាចមិនដាច់ផង ... ឯមេចោរកាន់បង្រួមដៃឱបរឹតកាយតូចតន់ដូចពស់ថ្លាន់រឹតកូនគោ ... ស្រាប់តែមានសំលេងគ្រហែមលាន់ឡើងជិតបង្កើយ។
មេចោរងើបមុខមើលទៅប្រភពសំលេង។ នាងក្រមុំក៏ងាកមើលទៅដែរ បានយល់បុរសឈ្មោះចំរុងកំពុងឈរកាន់ផ្គាមហាហង្សនៅក្បែរនោះឱ្យជ្រងោពុំដឹងជាមកដល់តាំងពីថ្មើរណា។
មេចោរស្នេងតាន់ស្រែកគំរាម "អាចោរចង្រៃ! មកឈររកងាប់អីនៅទីនេះ? ឆាប់ប្រាសអាយុចេញភ្លាមទៅ! តិចអញទាត់បែបថ្ងើមឥឡូវ! ... រឿងរបស់ប្តី-ប្រពន្ធអញទេវ៉ី កុំមកចង់ឈឺធ្នាល!"
"ឱសឱ លោកបងកំពុងតែប្រលោមប្រពន្ធទេឬ? ខ្ញុំស្មានថាជាចោរចេញមកចាប់កូនក្រមុំអ្នកស្រុកទាំងកណ្តាលថ្ងៃ..." នរៈលើកដៃសំពះដោយកាន់ទាំងទងផ្កាមហាហង្សជាប់ផង "ឱ្យខ្ញុំសុំទោសផងចុះលោកបង ... សូមលោកបងបន្តកិច្ចការទៀតចុះ ខ្ញុំលែងរំខានហើយ!..." ពោលចប់ គេបែរកាយបោះជំហានចាកចេញទៅមែន។
នារីតូចតន់ទម្លាក់បាច់ផ្កាចោល លើកដៃគក់ទ្រូងមេចោរវិញម្តង មាត់ស្រែក

ឃាត់បុរសឈ្មោះចំរុងផង "នែ៎ គាត់នោះឈប់សិន!..."

ឃើញនាយចំរុងនៅតែដើរចេញ យុវតីស្រែកខ្លាំងៗ "នាយចំរុងឈប់! ខ្ញុំមិនមែនជាប្រពន្ធអាចោរគម្រក់នេះទេ!"

នាយចំរុងក៏ទុចដំណើរ បែរមុខមកសួរវិញ "ហ្ហូ អីចឹងឬ? ... តើនាងអូនចង់ឱ្យបងធ្វើយ៉ាងម៉េច?"

"យីអើ! ... ចេះធ្វើល្ងីល្ងើទៅកើតដែរ! ... ឆាប់មកជួយខ្ញុំភ្លាមទៅ!" នារីពោលដោយគ្នាន់ក្នាញ់ ព្រមទាំងលើកជើងទាត់ស្នងមេចោរផាច់ៗផង ប៉ុន្តែពុំបានធ្វើឱ្យនាយស្នងតាន់ប្រែដំហរបន្តិចឡើយ។

ចំរុងឆ្លើយតបវិញ "យីអើហ្ន៎! ... មនុស្សជួបអាសន្នអន្ធក្រ ចង់សុំជំនួយ គេមិនដែលប្រើសម្តីទ្រគោះបោះបោកអីចឹងទេ! ... បើពោលពាក្យសុំដោយទន់ភ្លន់បន្តិច សូម្បីតែជីវិតក៏បងអាចលះបង់ឱ្យនាងអូនបានដែរ!"

មេចោរអស់សំណើច "វាងដូចក្តាមស្រែ ចង់មកតតាំងដណ្តើមស្រីជាមួយអញ? ចំជាមមាចមិនស្គាល់ភ្លើង! ... នាងអូនកុំរវល់នឹងអាចោលម្សៀតនោះ ឆាប់តាមបងតាមសម្រួលទៅណ៎ា!..."

នាយស្នងតាន់ចាប់ប្រអូសប្រទាញនាងក្រមុំ បម្រុងនាំចូលទៅក្នុងព្រៃ ធ្វើឱ្យស្រីតូចស្រែកយ៉ែៗ "នាយចំរុងមនុស្សចង្រៃ! ... ម៉េចមិនមកជួយយើងផង..."

"ប្រាប់ហើយ ថាឱ្យប្រើពាក្យសម្តីពិរោះពិសាជាមួយបន្តិចមក!..." នាយចំរុងឈរកាន់ផ្កាយ៉ាងព្រងើយនៅត្រង់កន្លែងដើម។

"បងចំរុង ជួយអូនផង!..." នារីស្រែកពីនាយ។

ចំរុងញញឹមស្រស់ លើកទងផ្កាមហាហង្សទៅទើរសៀតនឹងប្រគាបមែកឈើមួយ ហើយស្ទុះហក់ទៅផ្ទាញ! ... តែប្អូន-ប្រាំដង្ហើមប៉ុណ្ណោះ នាយយើងមកឈររាំងផ្លូវមេចោរស្រេច បន្ទីរវាចាលាន់ក្រឌី "សូមលោកបងដោះលែងនាងតូចនេះទៅ ហើយចាកចេញពីស្រុកនេះឱ្យឆាប់ ទើបបានសុខខ្លួន!"





មេចោរអស់សំណើចក្អាកក្អាយ "អាឯងអាងស្អី ទើបហ៊ានមកសម្តីថ្លោសដាក់មេចោរស្នងតាន់អញ?!..."

"ខ្ញុំមិនខ្វល់ថាលោកបងជាមេចោរស្នងតាន់ ឬស្នងប្រហោងអ្វីទេ..." ចំរុងពោលដោយទឹកមុខម៉ឺងម៉ាត់ "បើលោកបងមិនព្រមដោះលែងនាងតាមសម្រួល ខ្ញុំមានតែប្រើកម្លាំងវាយផ្តួលលោកបងជាមុនហើយ!"

មេចោរគ្រហឹមងិល ចាប់បង្វិលនារីក្នុងដៃទៅចំហៀងខាងឆ្វេងកាយ ហើយហក់ទៅលើកជើងវាត់ ទាត់ចំរុងផាំងៗ! ពីលើ ពីឆ្វេង ពីស្តាំ យ៉ាងញាប់រន្ទឺន ... បើចំរុងមិនរហ័សហក់លោតគេចនិងប្រើក្បាច់ជើងនិងដៃកាត់រងវិញយ៉ាងទាន់ពេល ម្ល៉េះសមនាយត្រូវបាក់កឬបាក់ចង្កេះស្លាប់ខានចាស់ស្រេច! ឃើញថាគូប្រយុទ្ធមិនមែនជាមនុស្សដំឡូងមូលដូចការស្មានពីដំបូងរបស់ខ្លួន មេចោរស្នងតាន់ក៏គ្រវាត់យុវតីក្នុងដៃចេញទៅម្ខាង ដោយមិនរវល់ថាបានធ្វើឱ្យនាងដួលបោកនឹងគល់ឈើស្ទើរទល់ផ្អកឡើយ។

លើកនេះមេចោរប្រើដៃនិងជើងវាយលុកមកលើគូប្រយុទ្ធយ៉ាងរហ័សផ្ទួនៗ តែចំរុងក៏នៅតែអាចការពារខ្លួនបានយ៉ាងមាំមួន ថែមទាំងអាចវាយបកទៅលើគូបដិបក្ខវិញផង ដំបូងនាយប្រើក្បាច់**ខ្លាក្រាប** ដោយលុតជង្គង់ស្តាំចុះដីលើកដៃឆ្វេងវាយរងកាត់ជើងស្តាំរបស់មេចោរដែលធាក់ចេញមករកខ្លួន រួចនាយស្ទុះហក់ឡើង ប្រើកណ្តាប់ដៃស្តាំដាល់ចូលទ្រូងរបស់មេចោរផាំង! មេចោរខ្ទាតថយក្រោយបន្តិច រួចឈរត្រង់ខ្លួន ប្រុងប្តូរក្បាច់ប្រយុទ្ធថ្មី តែចំរុងចូលទៅឈរកៀកនឹងចំហៀងកាយខាងឆ្វេងរបស់មេចោរយ៉ាងរហ័ស ជើងស្តាំប្រើក្បាច់**កងចក្រខ្មៅ**ជាន់សង្កត់លើជើងឆ្វេងរបស់មេចោរកុំឱ្យកម្រើកទាត់ចេញមកបាន ដៃឆ្វេងលូកទៅគ្រវីចុះឡើងតាមក្បាច់**មច្ឆាត្រលែងខ្លួន**

ចាំរាំងស្កាត់ការតដៃនៃមេចោរ ឯដៃស្តាំបត់ជាកែងតាមក្បាច់ឥសីបំបែកភ្នំ អុកទៅលើគល់ថ្គាមខាងឆ្វេងរបស់មេចោរផាំង! ... មេចោរទ្រេតទ្រោតបាត់លំនឹងរកកល់ចង់ដួល ឯចំរុងក៏ហក់ចេញឆ្ងាយបន្តិចពីកាយគូប្រយុទ្ធដើម្បីតាំងជំហរបស់ខ្លួននិងត្រៀមក្បាច់ជាថ្មីដែរ។

មេចោរលើកដៃអង្អែលថ្គាមដែលរងរបួសមុននឹងជូតឈាមដែលហូរចេញមកតាមចង្វែកមាត់ បើកភ្នែកសម្លក់ចំរុងដោយចំហាយចង់អាឃាតយ៉ាងសាហាវ ... ចំរុងក៏សម្ងឹងមុខគូប្រយុទ្ធវិញដោយឥតញញើត ស្តែងចេញនូវឧត្តមភាពនិងការជឿជាក់លើខ្លួនឯង។

ទំនងជាដឹងជាក់ថាមិនអាចប្រើគុនដៃជើងយកជ័យលើចំរុងបានទេ មេចោរក៏លើកដៃបម្រុងចាប់ដកដាវដែលស្ពាយលើខ្នង ... ប៉ុន្តែចំរុងហាក់មើលធ្លុះដល់គំនិតមេចោរជាមុន នាយស្ទុះរត់តម្រង់គូបដិបក្ខយ៉ាងលឿនដូចខ្យល់ ហើយយកជើងឆ្វេងជាក់ចុងភ្លៅខាងស្តាំរបស់មេចោរតាមក្បាច់**បុកអង្រែ**ធ្វើឱ្យមេចោរអង្គុញជង្គង់ស្តាំដូចជាទម្រសម្រាប់ឱ្យចំរុងសម្រាលខ្លួនឡើងទៅដាក់ជើងឆ្វេងជាន់ពីលើតាំងជំហរ ... មេចោរស្មងតាន់មិនទាន់បានកាន់ប៉ះដងដាវផង ក៏បង្ខំចិត្តដកដៃមកការពារខ្លួនពីការវាយលុកសិន ... ប៉ុន្តែចំរុងមានកាយវិការរហ័សដូចផ្លេកបន្ទោរ នាយប្រើមេគុន**ហនុមានទូងស្គរ**ដោយផ្តុំក្បាច់**ជង្គង់ហោះ** គឺបុកក្បាលជង្គង់ស្តាំចូលទ្រូងមេចោរ ស្របជាមួយនឹងក្បាច់**កែងឆេះ** គឺលាដៃបាតឆ្វេងក្តោបក្បាលមេចោរពីក្រោយទាញឱ្យឱនមកមុខ អុកកែងដៃស្តាំទៅលើកញ្ចឹងករបស់មេចោរ ... មួយជង្គង់ផាំង! ស្របគ្នានឹងមួយកែងផាំង! ... រួចចំរុងហក់សម្រាលខ្លួនឡើងលើ ហើយក្រឡាស់កាយដាំដូងទម្លាក់ជើងចុះមកឈរលើដីវិញធ្លុប! ... ក្នុងពេលដែលមេចោរស្មងតាន់ខ្ទាតតើតៗទៅក្រោយ ហើយដួលដេកផ្ងារស្រទាង។





មិនឃើញមេចោរក្រោកមកតយុទ្ធទៀត ចំរុងក៏ដើរចូលទៅពិនិត្យមើល ទើបដឹងថានាយស្មងតាន់សន្លប់ទន់កបាត់មាត់ឈឹងទៅហើយ។ ចំរុងដកហូតយកដាវមេចោរមកកាន់មើលក្នុងដៃបន្តិច ទើបលើកគប់ចោលទៅក្នុងព្រៃ ហើយដើរមករកតរុណីដែលនៅអង្គុយលើដី មិនទាន់ក្រោករួចនៅឡើយ។ នរៈលូកដៃទាញស្បៃគ្របលើស្មានិងទ្រូងឱ្យនារីយ៉ាងរៀបរយ មុននឹងបន្ទឺសួរ “នាងអូនមិនអីទេឬ? ... តើមានត្រូវរបួសត្រង់ណាដែរទេ?”

នាងតូចគ្រវីក្បាលដោយទឹកមុខស្លេកស្លាំង ទំនងជានៅភ័យនិងភាន់ភាំងចំពោះព្រឹត្តិការណ៍ដែលកើតឡើងមុននេះនៅឡើយ។

ចំរុងជួយលើកនារីឱ្យក្រោកឈរឡើង ហើយជួយទាញកម្ទេចស្លឹកឈើផាប់ចេញពីសក់តរុណី ... ស្រីតូចក៏យកដៃបោសដីចេញពីសំពត់នាងដែរ រួចនាងឈ្ងោកមុខពោលតិចៗ “អរគុណលោក ... ដែលបានជួយយកអាសាខ្ញុំ”

ចំរុងគ្រវីក្បាល “ហៅថាលោកមិនយកទេ! ត្រូវហៅឱ្យបានទន់ភ្លន់ជាងនេះ”

យុវតីងើបមុខឡើង ចងចិញ្ចើមជាថ្មី “គ្រាន់តែធ្វើគុណាតិចតួចប៉ុណ្ណឹងសោះ ម្តេចលោកលន់ចង់បានការតបស្នងទៅវិញសម្បើមម្ល៉េះ?!...”

បុរសបើកភ្នែកធំៗ “យី ហ៊ានថាតិចតួចផង! ... ខំបញ្ចេញកម្លាំងកាយស្ទើនឹងបាយបីពេលទៅហើយ ... គ្រាន់តែប្តូរនឹងពាក្យថា «បង» មួយម៉ាត់ ក៏នាងអូនគិតថាសម្បើមដែរ?”

នារីធ្វើឈិះ “នរណាទៅដឹង ... មេចោរស្មងតាន់ស្អីគេហ្នឹងជាបក្សពួកតែមួយនឹងអ្នកឯងក៏ថាបាន! ទំនងជារួមដៃគ្នាលេងល្បែងបញ្ឆោតភ្នែកគេទេដឹង?”

នាយចំរុងធ្វើភ្នែកស្ញឹង ចំហមាត់ធ្លុងអស់មួយខណៈ ទើបស្រែកចេញបានតែពាក្យ អុញ?! មួយម៉ាត់ប៉ុណ្ណោះ។

ស្រីស្រស់ពោលបន្ត “គេរស់នៅទីនេះអស់មួយជាតិមកហើយ មិនដែលមាន

ផុរមាស់អ្វីសោះ ... លុះគ្រាន់តែលេចមុខអ្នកឯងជាមនុស្សចម្លែកមកដល់ ក៏លេចមុខមេចោរស្នងតាន់ស្អីនេះមកដល់ដែរ! វាមិនគាប់ជួនគ្នាពេកទេ?”

ដល់ពេលនាយចំរុងធ្វើមុខក្រញូវម្តង “មិនស្មានថាមនុស្សមានមុខមាត់ស្អាតបែរជាមានចិត្តអាក្រក់សាមាន្យបែបនេះសោះ! ... បើទោះជាមិនចង់តបស្នងគុណ ក៏មិនគួររិះរកឧបាយមកចោទប្រកាន់មនុស្សល្អបែបនេះដែរ ... បើដឹងថាជាមនុស្សអឺចឹង មិនខ្ចីជួយនាំតែខាតកម្លាំងឥតអំពើ ទុកឱ្យធ្វើប្រពន្ធមេចោរទៅទើបសម!”

ស្រាប់តែនារីពោលបបួលឡើង “ចង់បញ្ជាក់ភាពបរិសុទ្ធជាការងាយទេ! អ្នកត្រូវចាប់ចងមេចោរនេះនាំយកទៅប្រគល់ឱ្យលោកមេភូមជាមួយខ្ញុំ នោះទើបខ្ញុំព្រមជឿថាអ្នកពិតជាមនុស្សល្អមែន!”

ចំរុងងក់ក្បាលឆ្លើយភ្លាម “បាន! គ្រាន់តែរឿងប៉ុណ្ណឹង មិនឱ្យចាញ់ចិត្តទេ!... បើបានបញ្ជាក់ថាខ្ញុំជាមនុស្សបរិសុទ្ធពិតប្រាកដហើយ នាងអូនមិនគ្រាន់តែត្រូវសុំទោស និងហៅបងថា បង ឱ្យពេញមាត់ទេ តោងយល់ព្រមឱ្យបងចូលស្តីដណ្តឹងធ្វើជាប្រពន្ធបងផងដែរ ... តើហ៊ានទេ?”

“ម្តេចក៏ស្រួតម្ល៉េះ?...” នារីបើកភ្នែកធំៗ រួចនាងឈ្ងោកភក្ត្រស្រដីតិចៗ “ចុះបើគេមានប្តីរួចទៅហើយ តើធ្វើយ៉ាងម៉េច?”

“នាងអូនកុំកុហក!...” ចំរុងសម្លឹងនាងតូចចុះឡើងៗ សក់នាងបួងឡើងលើក្បាល បញ្ចេញគល់កល្អត្រសូល ... នាងស្លៀកសំពត់ទេសពណ៌ព្រីងទុំលាយនឹងផ្កាល្អិតៗពណ៌ស្វាទុំជាលម្អ ដាបែបសំឡុយធ្លាក់វែងស្រុងដល់កជើង ... ចង្កេះរាវដូចអង្រ្គង លើទ្រូងមានចងសំពត់ព្រៃពណ៌កំបោរក្រហមរុំខ្ចប់ដើមទ្រូងតូចក្តិនៃក្រមុំទើបឡើងខ្លួន និងមានស្បៃស្តើងពណ៌កញ្ជាក់ស្វាមួយផ្ទាំងគ្របបិទបាំងពីលើសាច់ស្មានិងខ្នង ... តាមមើលទំនង នាងជាក្រមុំ





ទើបចេញពីម្លប់ក្នុងពេលថ្មីៗនេះឯង និងទំនងជាកូនចៅក្នុងគ្រួសារអ្នកមានធនធានគ្រាន់បើផង ទាស់តែចម្លែកត្រង់ថានៅលើ-ក ត្រចៀក និងដើងដៃនៃនារីក្មេង ពុំមានពាក់គ្រឿងអលង្ការអ្វីសោះ គឺមានតែខ្សែក្រវាត់ប្រាក់ពាក់ជុំចង្កេះសំពត់ប៉ុណ្ណោះ ពុំដូចនារីទូទៅឡើយ ដែលទោះជាក្រយ៉ាងណាក៏គង់មានខ្សែកនិងក្រវិលជាអង្កាំឬទង់ហ្វ៊ាពាក់ជាលម្អដែរ។

ចំរុងពោលបន្ត “កុំមកប្រតិដ្ឋថាមានប្តីរួចទៅហើយ បងមិនជឿទេ! ... បើចិត្តមិនក្លាហាន មិនហ៊ានប្រឈមមុខនឹងការពិតទេ ក៏និយាយតាមត្រង់មកចុះ!”

នារីនៅទ្រឹងមួយខណៈ ក៏ងក់ក្បាល បញ្ចេញកិរិយាហានក្លា “យល់ព្រម!... ខ្ញុំក៏មិនឱ្យចាញ់ចិត្តអ្នកដែរ!”

ស្រុះស្រួលគ្នាកាលណា ចំរុងក៏ទៅរកបោចវល្លិមកចងមេចោរស្នងតាន់ជាប់ក្រញង់ ... មាណពចាប់លើកមេចោរដាក់លីលើស្មា ហើយងាករកនារីស្រដីថា “ទៅយើង!...” តែពុំយល់ស្រមោលតរុណីឡើយ។ មិនអស់ចិត្ត ចំរុងខំបង្វិលកាយស្រែកហៅ “នាងអូន?! ... នាងអូន!...” ក្រៅតែពីសូរខ្យល់ថ្ងូរហ៊ូៗ ស្នូរស្លឹកឈើរលាស់ខ្លួនតាមជំនោរលាន់សស្រិប និងសំលេងមែកឈើព្រៃយោលយោកទង្គិចសង្កៀតគ្នាចុះឡើងង៉ែតង៉ត ក្រោកក្រាកៗ ពុំមានសូរដទៃឆ្លើយតបនឹងការស្រែកហៅរបស់ចៅមាណពឡើយ។ ក្តៅចិត្តខ្លាំងក្រៃ ចំរុងក៏ទម្លាក់មេចោរពីលើស្មាទៅដីវិញប្រូស ហើយស្ទុះរត់ចេញទៅរកផ្លូវ ... ពេលរត់ហួសទីដែលនាយសៀតទើរទងផ្កាមហាហង្ស មុនពេលវាយជាមួយមេចោរស្នងតាន់ ចំរុងរត់បកមកវិញ ខំលូកដៃទៅរកប្រគាបឈើ ប៉ុន្តែសូម្បីតែសំណុំបុប្ផាក៏បាត់ដែរ!...

ចំរុងរត់ចេញទៅដល់ផ្លូវរទេះ ខំងាកមើលឆ្វេងមើលស្តាំ តែពុំយល់ស្រមោលក្រមុំតូចរូបស្រស់នោះឡើយ។

ពីរថ្ងៃក្រោយមក...

ចំរុងដើរចូលទៅក្នុងសាលាចម្លាក់មួយ តាំងនៅកណ្ដាលដីភូមិដ៏ធំទូលាយ មានរុក្ខជាតិតូចធំ ចោលម្លប់ត្រជាក់ល្ហឹមៗ ទីនេះគឺជាពេងជាងចម្លាក់ដ៏ល្បី ប្រចាំភូមិវាលវាលអន្លង់វិលផងនិងប្រចាំក្រុងពោធិសាត់ទាំងមូលផង មានបើកទទួលឆ្លាក់គ្រឿងចម្លាក់ផ្សេងៗ និងបង្ហាត់បង្រៀនសិស្សចម្លាក់ជាបុរសយ៉ាងច្រើនកុះករ ... ព្រះសុរិយាទើបតែរះផុតចុងព្រឹក្សា ឯសិស្សនិងជាងចម្លាក់ទាំងឡាយកាន់កិច្ចការតាមមុខនាទីយ៉ាងសកម្មជាស្រេច ... ខ្លះឆ្លាក់ថ្មកែវ ខ្លះឆ្លាក់ថ្មភ្នំ ខ្លះឆ្លាក់ឈើ ខ្លះឆ្លាក់លើផ្ទាំងស្បែក ខ្លះឆ្លាក់លើលោហៈមានមាស ប្រាក់ ស្ពាន់ជាដើម ... ខ្លះឆ្លាក់ព្រះពុទ្ធរូប ទេវរូប និងរូបមនុស្សសត្វ ផ្កាភ្ញីផ្សេងៗ ... ឯខ្លះឆ្លាក់លើឧបករណ៍ប្រើប្រាស់តូចធំតាមក្បាច់ក្បូរយ៉ាងសម្បូរបែបៗ

ចំរុងដើរចូលដល់កណ្ដាលសាលាធំ ក៏លេចបុរសម្នាក់មានក្បាលត្រងោលចេញមុខមកទទួលរាក់ទាក់និងពោលសួរនាំយ៉ាងគួរសម ថាតើបុរសយើងមានបំណងមកបង្គាប់ឱ្យឆ្លាក់អ្វី ឬមករកទិញចម្លាក់ដែលមានស្រាប់ ឬមកសុំរៀនយកអាជីពជាជាងចម្លាក់?

ចំរុងឆ្លើយតបវិញថានាយមករកមេជាងចម្លាក់ណាដែលមានជំនាញជាងគេ ដើម្បីសុំឱ្យជួយឆ្លាប់រូបមនុស្សតាមគំរូក្នុងផ្ទាំងគំនូរៗ

បុរសត្រងោលក៏នាំចំរុងទៅជួបបុរសចំណាស់មួយរូប មានឫកពារជាអ្នកធំកំពុងឈរបីតខ្សៀរនិងចេញបញ្ជាបង្ហាត់បង្ហាញដល់សិស្សចម្លាក់ម្នាក់ៗ

នាយត្រងោលលើកដៃសំពះ ពោលទៅកាន់បុរសចំណាស់ដោយក្ដីគោរព "ជម្រាបប្រសាសន៍ លោកតា ... មានគេរកជាងជំនាញឱ្យឆ្លាក់រូប"

ពេលតាចាស់ងាកមករក ចំរុងក៏លើកដៃសំពះដែរ "ជម្រាបសួស្ដីលោកតា!"





តាចាស់ដកខ្សៀរចេញពីមាត់ លើកដៃសំពះសងវិញ "ល្អហើយចៅប្រុស! តើចៅចង់ឱ្យឆ្លាក់រូបអ្វីដែរ?"

"បាទ៎ លោកតា ... ខ្ញុំចង់បានរូបចម្លាក់ឈើមួយជំហរមនុស្ស តាមលំនាំរូបក្នុងគំនូរនេះបាទ៎..." ចំរុងលើករមូរសំពត់គំនូរដោយដៃទាំងពីរហុចចេញទៅៗ

តាចាស់លើកខ្សៀរទៅដាក់មាត់បឺតមួយហឺតសិន ទើបពោល "ឱ្យតាសុំមើលគំរូក្នុងគំនូរបន្តិចមកអីចឹង!..." គាត់លូកដៃមកទទួលរមូរកំណាត់សំពត់យកទៅលាមើល ស្រាប់តែធ្វើមុខស្រឡាំងកាំង ស្ទើររបូតខ្សៀរចេញពីមាត់ធ្លាក់ទៅដីបាត់ តែគាត់រហ័សចាប់យកទៅកាន់នៅដៃម្ខាងទាន់ មុននឹងកាន់ផ្ទាំងគំនូរត្រដាងជាថ្មី ... តាចាស់បើកភ្នែកធំៗ លាន់មាត់ឮៗ "នេះ ... នេះ ... ជារូបនាងមាលាវតី ចៅស្រីរបស់អញទេតើ!..." បុរសចំណាស់បត់ផ្ទប់មុខផ្ទាំងគំនូរចូលគ្នា ដៃស្ដាំលើកខ្សៀរចង្អុលមុខចំរុង "ឯងដឹងហើយមែនទេថាមាលាវតីជាចៅស្រីរបស់អញ?..." តាចាស់សម្លក់ចំរុងឡើងភ្នែក "ឯងហ៊ានព្រហើនយករូបចៅស្រីអញ មកឱ្យអញឆ្លាក់រូបឱ្យផង?! ... ផ្ដេសផ្ដាស!..."

ចំរុងប្រញាប់លើកដៃសំពះ "ខ្ញុំបាទ សុំទោសណ៎ាលោកតា ... ខ្ញុំបាទពុំបានដឹងថា អ្នកនាងម្នាក់នេះជាចៅស្រីរបស់លោកតាទេ ... ខ្ញុំបាទបានជួបនាងដោយចៃដន្យ ទើបគូររូបនាងចេញមក និងចង់ឱ្យគេឆ្លាក់រូបនារីដ៏បវរនេះតាមចំណូលចិត្តជាសិល្បករប៉ុណ្ណោះ ... ខ្ញុំបាទពុំមានចេតនាមើលងាយមើលថោកលោកតានិងអ្នកនាងម្ចាស់រូបទេ..."

តាចាស់ស្រែកសន្ធាប់ "យើស! ... មិនបាច់មកយកលេសទេ! ... អញដឹងឫកពួកអាដែងកំលោះៗអត់ពូជឯងច្បាស់ណាស់ ... ម៉្លៗមិនចេះធ្វើការងារអ្វីឱ្យមានប្រយោជន៍ទេ ចេះតែដើរប៉ោឡៃតាមចៅស្រីអញ ... ឫករាក់កំភែលរបៀបនេះ កុំសង្ឃឹមថាអញព្រមលើកចៅស្រីឱ្យ! ... ឆាប់ចេញពីមុខពីមាត់

អញភ្ញាមទៅ! តិចអញរកដំបងមកសំពងឱ្យបែកក្បាលឥឡូវហើយ!...”

ចំរុងមុខស្មាំង ប្រឹងលើកដៃសំពះ តែចាស់ស្រែកសន្ធាប់ទៀត “ចេញទៅ!... មិនបាច់មកប្រឹងសំពះសំពិនស្អីទេ!”

ចំរុងលើកដៃដែលកំពុងសំពះ ចង្អុលទៅផ្ទាំងគំនូរលើដៃតាចាស់ “ខ្ញុំបាទសុំ គំនូររបស់ខ្ញុំបាទមកវិញ ណ៎ាលោកតា...”

“ស្អី! ... មានមុខមកសុំយកគំនូរទៅវិញផង?!...” តាចាស់ឡើងញ័រខ្លួន “អញ មិនឱ្យអាឯងយករូបចៅស្រីរបស់អញទៅដើរបង្អួតគេឯងលេងពាសវាល ពាសកាលនោះទេ! ... បើមិនឆាប់បកក្បាលចេញទៅវិញទេ អញរកព្រនង់ ដេញសំពងឱ្យផាប់ខានចាស់ឥឡូវ! ... ទៅឬមិនទៅ?!...”

“ទៅ! បាទ៎ ទៅ!...” ចំរុងបែរខ្លួនរកច្រករត់ចេញពីសាលាចម្លាក់តាមបញ្ជា។ ទាល់តែចេញមកដល់មាត់ផ្លូវ ទើបមាណពហ៊ានពោលរអ៊ូរទាំ “ព្រះអើយ! មិនដែលឃើញមនុស្សស្អីកាចសាហាវឃោរឃៅ ហួងហែងចៅដូចឆ្កែហួង ហែងឆ្អឹង! ... រំលោភយករូបគំនូរឯងខំគូរអស់ពីរយប់ពីរថ្ងៃមិនបានដេក មិនបានពួនទៅបាត់ ... ចង្រៃយក៏! ... កុំតែយល់ថាជាចាស់ទុំ កុំអីលេងឱ្យ ស្គាល់ស្នាដៃអាចំរុងម្តង ... ទាំងជីតា ទាំងចៅស្រី សុទ្ធតែចិត្តអាក្រក់អាក្រី សម្តីកាចដូចគ្នា ... នេះពិតជាអម្បូរមនុស្សកំពោលមែនៗហើយ!...”

ចំរុងកំពុងតែដើរឈ្ងោកមុខ រអ៊ូរទាំង៉ឹកង៉ុកៗម្នាក់ឯង ស្រាប់តែមាននរណា ម្នាក់ដើរកាត់តាមផ្លូវប្រាសគ្នានឹងដំណើរនាយទៅ ... ដំបូងចំរុងមិនបានចាប់ ភ្ញឹកទេ តែគន្ធពិដោរដែលរសាត់តាមខ្យល់យ៉ាងស្រាលមកប៉ះនាសិក ធ្វើ ឱ្យមាណពនឹកឃើញដល់មនុស្សម្នាក់ បេះដូងនាយលោតខុសចង្វាក់...។

ចំរុងប្រញាប់បែរក្រោយ ស្រែកហៅ “មាលាវតី!...”

អ្នកដើរនៅខាងមុខក៏ឈប់ង៉ក់! តែពេលបែរក្រោយ បានឃើញមុខចំរុងភ្ញាម



ក៏បែរទៅវិញ ដាក់មេផាយចេញក្តួង!

ចំរុងរត់តាមប្រិប! ... តែប៉ុន្មានជង្ហើមប៉ុណ្ណោះ មាណពចាប់ដៃមាលាវតីបាន ស្រេច “ស្រីកំហូច! ... ចង់លួចរត់គេចទៅណាទៀត?”

មាលាវតីខំរើ ខំទាញកន្ត្រាក់ដៃនាងចេញមកវិញ តែកណ្តាប់ដៃបុរសរឹងមាំ ដូចតង្កៀបដែក “លែង! លែង!... យី ម្តេចព្រហើន ហ៊ានមកចាប់ដៃគេ កណ្តាលផ្លូវ ... តិចខ្ញុំស្រែកឱ្យផ្អើលគេឥឡូវ!...”

“ស្រែកទៅ!...” ចំរុងពោលបញ្ឆោះ “ស្រែកឱ្យផ្អើលគេ ស្រែកឱ្យផ្អើលទាំង ជីតានាង ឱ្យលោកចេញពីសាលាចម្លាក់មកចុះ នោះខ្ញុំនឹងបានរៀបរាប់ ជម្រាបលោកពីរឿងមេចោរស្នងតាន់ ... ពីរឿងនាងមិនប្រកាន់សច្ចៈ រមិល គុណចំពោះអ្នកដែលប្តូរជីវិតជួយសង្គ្រោះនាង...”

មាលាវតីឈប់រើ បើកភ្នែកធំៗ “លោកតា?! ... លោកស្គាល់លោកតារបស់ខ្ញុំ?”

“មិនត្រឹមតែស្គាល់តិចតួចទេ ... ថែមទាំងបានរាប់អានគ្នាយ៉ាងជិតស្និទ្ធផង! ឬអូនមាលាវតីចង់ចូលទៅជួបលោកតាក្នុងពេលឥឡូវហ្នឹង?...” ចំរុងលើក ដៃម្ខាងចង្អុលទៅសាលាចម្លាក់។

ក្រមុំតូចរហ័សតប “កុំអី! ... ខ្ញុំមិនចង់ឱ្យលោកតាព្រួយភ័យព្រោះតែខ្ញុំទេ... តើលោកចង់យ៉ាងម៉េច?”

ចំរុងញញឹម “រឿងទីមួយ សុំឱ្យនាងអូនឈប់ហៅបងថានាយឬលោកទៀត តើយល់ព្រមទេនាងអូនមាលាវតី?”

“ចាស៎...” នារីឆ្លើយយ៉ាងខ្សោយនិងឈ្ងោកមុខជ្រប់។

“ចាស៎ ទាំងកំបុតថ្ពុយអីចឹង បងមិនយកទេ!”

“ចាស៎ បងចំរុង!” នារីពោលដោយសំលេងកាន់ខ្សោយជាងមុន។

ចំរុងនឹកចង់អស់សំណើច តែខំទប់ “ឯរឿងទីពីរ គឺបងសុំឱ្យនាងអូនកំដរបង

ដើរកំសាន្តព្រៃជាយភូមិក្បែរមាត់អូរដែលពួកយើងបានជួបគ្នាដំបូងនោះ មួយថ្ងៃ តើបានទេប្អូនមាលាវតី?"

"ចាស៎ បងចំរុង..." ក្រមុំតូចឆ្លើយដោយមុខកាន់តែមិនសប្បាយចិត្ត "តែសុំកាត់ពេលមួយថ្ងៃមកត្រឹមកន្លះថ្ងៃបានហើយ ព្រោះពេលនេះខ្ញុំមានការត្រូវទៅផ្សាររកទិញរបស់របរប្រើប្រាស់ខ្លះ..."

ចំរុងញញឹមពព្រាយ "បងក៏ចង់ទៅឃើញផ្សារដែរ ចាំបងកំដរនាងអូន..."

"មិនបានទេ!..." មាលាពោលកាត់សម្ដីចំរុងដោយអាការស្ទន់ស្ទា "បើមានគេឃើញខ្ញុំបណ្ដើរប្រុសឈ្នោលដើររហេតរហូតតាមផ្សារ លោកតាមុខតែវាយខ្ញុំស្លាប់ពុំខាន!..."

ចំរុងឥតសង្ស័យលើសម្ដីនាងក្រមុំឡើយ នាយស្រមៃដល់មុខលោកតានិងសម្រែកគំរាមរបស់គាត់មុននេះធ្វើឱ្យនាយភ័យស្ទើរលស់ព្រលឹង ... នរៈក៏ប្រញាប់សម្របសម្រួល "ណ្ហើយ បងមិនទៅផ្សារជាមួយនាងអូនក៏បាន តែពេលថ្ងៃត្រង់ នាងអូនត្រូវទៅជួបបងនៅក្រោមដើមមហាហង្សក្បែរមាត់អូរកន្លែងដែលយើងជួបគ្នាដំបូងជាកំហិត! បើហ៊ានលេងល្បិចអ្វី ឬមិនទៅតាមណាត់ បងចំរុងមិនទុកមុខឱ្យទេណ៎ា! ... បងស្គាល់លោកតាច្បាស់ បើឱ្យបងតាមទារបំណុលដល់ផ្ទះ នាងអូនមុខតែខាតធំ ... កុំថាបងមិនបានប្រាប់!"

គ្រាន់តែចំរុងលែងដៃនាងភ្លាម មាលាក៏ស្ទុះដើរចេញទៅទាំងមុខក្រញូវ។

វេលាថ្ងៃត្រង់មកដល់ ... ចំរុងអង្គុយលើដង្គត់ឈើមួយ ប្រែដំបុតកង្កែបអាំងនិងត្រីអាំងលើរងើកភ្លើងឆ្អក់បណ្ដើរ គិតក្នុងចិត្តបណ្ដើរ "បើនាងមាលាវតីបានដឹងរឿងពិតថាយើងឥតបានស្គាល់រាប់អានមានមេត្រីអ្វីនឹងលោកតារបស់នាងទេ តើនាងនឹងមកជួបយើងតាមការណាត់ទេហ្ន៎?..." បុរសញញឹម





"នាងប្រាកដជាមក! ... បើនាងមិនទាន់ដឹងការពិត នាងមិនហ៊ានខកណាត់ទេ ព្រោះខ្លាចយើងយករឿងនាងទៅជម្រាបលោកតា ... តែបើដឹងការពិតស្រីឆ្នាស់ហ្នឹងច្បាស់ជាមកតាមរករឿងយើងឱ្យដឹងសខ្មៅមិនលែង..."

រំពេចនោះ មានស្នូរជើងជាន់លើស្លឹកឈើក្រៀមលាន់ស្រិបៗតិចៗ ... ចំរុងងើបមុខមើលទៅ ក៏បានយល់នាងមាលាវតីកំពុងតែដើរចូលមកមែន!

មាណពបន្ថែមស្នាមញញឹមលើផ្ទៃមុខ ស្រដីរាក់ទាក់ "សួស្ដីនាងអូន!"

មាណវីមិនស្ដីតបវិញទេ មុខកាន់តែក្រញូវ ... នាងដើរមកឈរទល់មុខចំរុងនៅចំហៀងម្ខាងទៀតនៃភ្នក់ភ្លើង។

បុរសងើយមុខ ពោលចំអន់ "នាងអូនឈឺពោះឬ បានជាមុខមិនរីក?"

នារីចងចិញ្ចើម ពោលបែបគ្នាន់ក្នាញ់ "អត់ឈឺពោះទេ តែឈឺចិត្ត!"

ចំរុងញញឹមដដែល "សូមអរគុណដែលនាងអូនស្ម័គ្រមកតាមការណាត់"

នារីធ្វើហ៊ឹះបន្តិច "ខ្ញុំមិនបានស្ម័គ្រមកតាមការណាត់អ្វីទេ! ... លោកឯងនេះអាក្រក់ណាស់ អាងតែមានចំណុចខ្សោយគេក្នុងដៃ ក៏ចាប់បង្ខំគេអត់ប្រណី! ចាំមើលមុខតែមានពៀរធ្លាក់នរកមិនខានទេ! ... ថ្ងៃក្រោយ ពេលមានកូនស្រីសូមឱ្យមានប្រុសចង្រៃតាមធ្វើបាបវិញកុំខានឱ្យសោះ!"

ចំរុងលួចសើចក្នុងពោះ "នាងមិនទាន់ដឹងការពិតទេ..." តែនាយញញឹមបែបហី "មនុស្សមាត់អាក្រក់ ពូកែដាក់បណ្ដាសាគេ ដូចជានាងអូននេះ ក៏កុំសង្ឃឹមថាអាចគេចពីធ្លាក់នរកបាន ... ពួកយើងមានសន្ដានប្រហែលគ្នាទេ គួរតែចងមិត្តនឹងគ្នា ក្រែងទៅដល់ឋាននរកមិនសូវអផ្សុក!"

នារីធ្វើហ៊ឹះ "មនុស្សអាក្រក់ដូចលោកឯង..."

"អាហ៊ែម! ..." ចំរុងគ្រហែមកាត់សម្ដីនាងក្រមុំ "លោកទៀតហើយ?!..."

"មនុស្សអាក្រក់ដូចបងចំរុងឯង..." មាលាកែសម្ដី "មុខតែធ្លាក់ឋាននរកជ្រៅ

ជាងខ្ញុំ ... ដូច្នេះកុំសង្ឃឹមថាបានជួបខ្ញុំឱ្យសោះ!"
ចំរុងអស់សំណើច "ដ្បិតតែអីចឹងហើយ ទើបបងចង់ជួបនាងអូនក្នុងពេលមានជីវិតនេះអី!..." បុរសស្រដីបញ្ចុះបញ្ចូល "កុំខឹងអី ... គ្រាន់តែកំដរបងកន្លះថ្ងៃ មិនខូចបង់អ្វីទេ ... បងជានារក្សាការពារនាងអូនឱ្យល្អបំផុត! បើមិនពិតដូចសម្ដី សូមឱ្យអារុក្ខអារក្ខប្រល័យជន្មជីវ៉ាបង់អសារទៅចុះ!"
រវល់តែជជែក ចំរុងភ្លេចប្រែដំបុតលើភ្នក់ បណ្ដាលឱ្យកង្កែបនិងត្រីផ្ទក់ត្រីក្រាញ់អាំងខ្លោចឡើងហុយផ្សែងខ្មៅ ឈ្ងៀមឡប់ ... ទម្រាំតែមាណពភ្ញាក់អាត្មា "ម៉ែកូនអើយ! ខ្លោចអស់ហើយ!..." ចំរុងចាប់លើកដំបុតចេញពីភ្នក់។
មាលាអស់សំណើច "សមមុខ! ... នេះហើយគេថាកម្មពៀរតាមទាន់ហន់!"
"កុំអាលសប្បាយចិត្តពេក!..." ចំរុងពោលតបវិញ "គឺយើងមានកម្មពៀរជាមួយគ្នាហ្នឹងឯង ... នាងអូនក៏ត្រូវបរិភោគអាហារខ្លោចកំដរបងដែរ..."
"ខ្ញុំមិនឃ្លានទេ!..." នារីប្រកែក។
"មិនឃ្លានក៏ត្រូវតែហូបដែរ! នាងអូនអង្គុយចុះមក!..." មាណពចង្អុលទៅដង្គត់ឈើមួយនៅក្បែរនោះ។
មាលាដើរទៅដាក់បង្គុយតាមបញ្ជា ហើយលូកដៃទទួលយកដំបុតត្រីខ្លោចទៅកាន់ទាំងមុខស្អុយប៉ែ។
ចំរុងបេះភ្លៅកង្កែបមួយមកដាក់មាត់ទំពា ហើយធ្វើមុខបែបភ្ញាក់ "យី ឆ្ងាញ់មួយបែបទេតើ! ឈ្ងុយហើយស្រួយផង! ... សាកមើលទេនាងអូន?" នាយបេះភ្លោះកង្កែបម្ខាងទៀតហុចទៅឱ្យនាងក្រមុំ។
នារីទទួលយកមកដាក់មាត់ទំពាទាំងអាការទើសទាល់។
ចំរុងញញឹមសួរ "ឆ្ងាញ់ទេ?"
មាលាឆ្លើយយ៉ាងខ្ញីថា "អត់!..."





"អីចឹងសាកអានេះម្ដង!..." ចំរុងកាច់កន្ទុយត្រីផ្ទក់ហុចឱ្យតូចតន់។
មាលាទទួលយកមកកាន់ លុះចំរុងរវល់ឈ្ងោកមុខបេះក្បាលត្រីដាក់មាត់ខ្លួនឯង នារីគ្រវែងកន្ទុយត្រីចោលទៅក្នុងគុម្ពស្មៅបាត់ ... ដល់ចំរុងងើបមុខឡើង នារីធ្វើជាលើកដៃដាក់មាត់ហើយធ្វើជាទំពាផង។
ក្រោយពេលបរិភោគអាហារខ្លោចឆ្អែតឆ្អន់ហើយ ចំរុងនាំស្រីតូចដើរកំសាន្តតាមមាត់គង្គា នាំនាងជជែកសួនាំពីនេះពីនោះពុំដាច់ ... មាលាក៏ចាប់ផ្ដើមបន្ទន់ឥរិយាបថដាក់មាណពជាបណ្ដើរៗ លែងសូវប្រើសម្ដីរម៉ាំងរម៉ោកដូចមុនទៀត។ លុះចំរុងប្រាប់នាងថានាយមកពីស្រុកបាកាណ មាលាស្រាប់តែសួរឡើង "បងជាសិស្សមកពីសាលាទិសាបាមោក្ខ តើមែនឬទេ?"
ចំរុងងាកសម្លឹងមុខនាងក្រមុំបែបភ្ញាក់ "ម្ដេចនាងអូនដឹង?"
មាលាញញឹម "គឺសម្គាល់ទៅតាមសំនួនវោហារ និងតាមក្បាច់គុនដ៏អស្ចារ្យរបស់បងពេលវាយជាមួយមេចោរស្នេងតាន់នោះអី! ... បងមុខតែមិនមែនជាអ្នកស្រុកបាកាណធម្មតាឡើយ!"
បាកាណជាទីប្រជុំជនដ៏ល្បីប្រចាំខេត្តពោធិ៍សាត់ ព្រោះមានតាំងបន្ទាយពលដ៏ធំមួយរបស់ព្រះរាជា និងមានសាលាដ៏ល្បីមួយមានឈ្មោះថា **ទិសាបាមោក្ខ** មានសិស្សមកពីទីជិតឆ្ងាយចូលកាយមកសិក្សាហាត់រៀនចំណេះវិជ្ជាផ្សេងៗតាំងពីអក្សរសាស្ត្រ វេជ្ជសាស្ត្រ (ការផ្សំថ្នាំនិងកែរោគ) វិចិត្រកម្ម (ចម្លាក់និងគំនូរ) និងយុទ្ធគុន ជាពិសេសក្បាច់ប្រដាល់និងល្បុក្កតោខ្មែរដ៏អស្ចារ្យ។
ចំរុងញញឹមបែបអៀនម្ដង "បងជាសិស្សសាលាទិសាបាមោក្ខមែន តែជាអ្នកស្រុកបាកាណធម្មតា ... ពុំបានវិសេសអស្ចារ្យអ្វីដូចនាងអូនគិតឡើយ!"
មាលាសម្លឹងមុខបុរសដោយទឹកមុខកាន់តែកោតគោរពជាងមុន "គេថាអ្នកចេះដឹង ប្រឹងដាក់ខ្លួន ... មានតែអ្នកល្ងង់ឆោត ទើបខំអួតអាងឱ្យគេកោត!"

ចំរុងសម្លឹងមុខនារីដោយកែវភ្នែកកោតសរសើរដែរ "នាងអូនជាមនុស្សបានវោហារ ... ទំនងជាអ្នកចេះដឹងដ៏អស្ចារ្យ..."

មាលាត្រវីក្បាល ស្រដីកាត់ "កើតជាកូនស្រី តើទៅបានរៀនសូត្រចេះដឹងអីដូចកូនប្រុស ... ខ្ញុំបានឮឈ្មោះល្បីនៃសាលាទិសាបាមោក្ខ ក៏មានចិត្តចង់ទៅសិក្សានៅទីនោះដែរ តែលោកតាមានប្រសាសន៍ថាសាលាបើកទទួលតែសិស្សជាបុរសភេទ ... ខ្ញុំបានរៀនអក្សររៀនលេខតិចតួចនៅផ្ទះ ... បានអានសាស្ត្រាតិចតួច ... ខ្ញុំក៏ចង់មានចំណេះ ចង់ចេះក្បាច់គុនពូកែ ... តែពុំអាចប្រឆាំងនឹងវាសនាកើតមកជាស្រីបាន..."

ចំរុងពោលលួងលោម "នាងអូនកុំតូចចិត្តតូចថ្លើមថ្វី ... មុខងារមនុស្សស្រីនៅក្នុងគ្រួសារក៏សំខាន់ តាំងពីកាន់ការរក្សាផ្ទះសម្បែង ទុកដាក់ទ្រព្យសម្បត្តិនិងឃុំគ្រងកូនចៅបាវព្រាវ ... មនុស្សប្រុសច្រើនពូកែតែចំពោះកិច្ចការខាងក្រៅប៉ុណ្ណោះ ... បើគ្មានមនុស្សស្រីល្អនៅក្នុងផ្ទះ ជាភរិយាល្អ ជាមាតាល្អ ជាម្ចាស់ស្រីល្អ ... គ្រួសារមុខតែពុំមានក្ដីសុខសប្បាយឡើយ ... ជាពិសេសនាងអូនក៏ដឹងច្បាស់ កូនស្រីនាំបណ្ណាការចូលផ្ទះ បានថ្លៃទឹកដោះសងគុណម្ដាយផងណ៎ា ... មិនដូចកូនប្រុសទេ!..."

មាលាញញឹមឡើងវិញ "ស្ដាប់ទៅដូចជាបងចំរុងប្រណែននឹងមនុស្សស្រី?"

ចំរុងញញឹមតបវិញ "គឺប្រណែនខ្លះៗដែរហ្នឹងណ៎ា..."

មាលាបំបែរកិច្ចសន្ទនាទៅរឿងថ្មី "បងចំរុងមកធ្វើអីនៅភូមិខ្ញុំ?"

ចំរុងរៀបរាប់ "លោកគ្រូរបស់បងបានបញ្ជូនបងឱ្យមកគូរគំនូរពុទ្ធជាតកលើជញ្ជាំងនិងពិដានព្រះវិហារវត្តពោធិវាល អស់ពេលជាងបីខែមកហើយ... បងទើបតែបញ្ចប់ការងារកាលពីបីថ្ងៃមុននេះឯង ... ប៉ុន្តែព្រះគ្រូសង្រ្គាជជុំលោកមានដីកាឃាត់ឱ្យបងនៅលេងបុណ្យលយកន្ទងនិងសំពះព្រះខែសិន





សឹមឱ្យបងត្រលប់ទៅបាកាណវិញ!"

មាលាសម្លឹងមុខចំរុងដោយក្ដីភ្ញាក់ផ្អើលនិងស្ញប់ស្ញែង "ឱ បងគឺជាវិចិត្រករជាម្ចាស់ស្នាដៃគំនូរក្នុងព្រះវិហារវត្តពោធិវាល?"

នរៈសម្លឹងមុខនារីបែបភ្ញាក់ដែរ "អូនបានឃើញរូបគំនូរទាំងនោះហើយ?"

"ចាស៎ ... គឺកាលពីម្សិលម៉្ងៃនេះឯង ... បងខ្ញុំម្នាក់ទើបតែលាចាកផ្នួស ... ព្រះគ្រូចៅអធិការជុំលោកបានអនុញ្ញាតឱ្យពួកខ្ញុំយកគ្រឿងសក្ការបូជាទៅថ្វាយបង្គំព្រះអង្គធំនៅក្នុងព្រះវិហារ ដែលបានបិទទ្វារដើម្បីឱ្យវិចិត្រករគូរគំនូរពុទ្ធជាតកអស់មួយរយៈពេលដ៏ធំមកហើយ ... ឱ ខ្ញុំពេញចិត្តនឹងស្នាដៃគំនូរអ្វីម៉្លេះ! ... រូបភាពរស់រវើក ហាក់មានជីវិតពិតៗ ... មិនស្មានថាខ្ញុំបានជួបមុខម្ចាស់ស្នាដៃសោះ..." មាលាញញឹមពព្រាយ "ឥឡូវខ្ញុំយល់ហើយ!..."

"យល់រឿងអីទៅនាងអូន?..." ចំរុងងាកមុខសួរនារី។

មាលាសម្លឹងមុខមាណពដោយកែវភ្នែកភ្លឺផ្លេក "អីចឹងទេតើ ទើបលោកបងស្គាល់និងរាប់អានគ្នាជាមួយលោកតារបស់ខ្ញុំ ... លោកតានិងសិស្សជំនាញៗរបស់គាត់ជាអ្នកឆ្លាក់រូបសំណាកផ្សេងៗតាំងនៅទូទាំងបរិវេណវត្តពោធិវាល!"

ចំរុងទម្លាក់មុខជ្រប់ "នាងអូនហ្ន៎ា..."

"ចាស៎...?" នារីខំតាមសម្លឹងមុខបុរស។

មាណពបន្ទីដោយសំលេងខ្សោយៗ "បងមានរឿងត្រូវសារភាព..."

បេះដូងមាលាលោតខុសចង្វាក់ "សារភាពរឿងអី បងចំរុង?"

"គឺ ... គឺ ... បង ... បងបាននិយាយកុហកនាងអូន..." ចំរុងងើបសម្លឹងមុខនាងក្រមុំដោយកែវភ្នែកស្រងូតស្រងាត់។

មាលាមានទឹកមុខភាន់ភាំងស្រឡាំងកាំង "បង ... បងនិយាយកុហកខ្ញុំពីរឿងអី? ... ការពិតបងពុំមែនជាវិចិត្រករ ពុំមែនជាម្ចាស់ស្នាដៃគំនូរទេឬ?"

មាណពប្រញាប់ពោល "បងជាជាងគំនូរពិតមែន ... តែបងពុំដែលស្គាល់គ្នាជិតស្និទ្ធនឹងលោកតារបស់អូន ... បងពុំដែលបានរាប់អាននឹងលោកទេ ... បងទើបតែបានជួបមុខលោកម្ដងកាលពីព្រឹកមិញនេះឯង ... គឺក្រោយពេលបងបានជួបអូនកាលពីម្សិលម៉្ងៃ ... ចិត្តបងជាប់ជំពាក់នឹងរូបអូនជាខ្លាំងក្រៃ តែបងគ្មានសង្ឃឹមថាបងបានជួបអូនទៀតទេ បងក៏គូររូបអូនចេញមក ... រួចហើយបងយកផ្ទាំងគំនូរទៅរកជាងជំនាញដើម្បីឱ្យឆ្លាក់ចេញជារូបចម្លាក់ គ្រាន់បានយកជាប់ខ្លួនពេលបងត្រលប់ទៅបាកាណវិញ ... ទើបបងបានជួបលោកតារបស់អូននៅសាលាចម្លាក់ ... លោកតាខឹងនឹងបងខ្លាំងណាស់គាត់..." មាណពងាកតាមសម្លឹងមើលក្រមុំតូចតន់ ដែលបែរខ្លួនរត់ចេញទៅដោយពុំនៅចាំស្ដាប់រឿងរបស់ចំរុងដល់ចប់ឡើយ។ ចំរុងនៅឈរទ្រឹងមួយកន្ទែង ហើយនាយស្រែកតាមពីក្រោយនារីទៅថា "មាលាវតី បងសុំទោស!"